**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៧២៨២ សហវ.វស

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩

**គោរពជូន**

**ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ**

**គ្រប់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជា**

**កម្មវត្ថុ** : ករណីការរួមចំណែកបដិភាគរបស់រាជរដ្ឋាភិបាល ទៅនឹងគម្រោងដែលហិរញ្ញប្បទានផ្ទាល់ដោយបណ្តាប្រទេសស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ អង្គការមនុស្សធម៌ និងសប្បុរសជននានា ។

**យោង** : - ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ។

- លិខិតលេខ ៧៨៣៨ សហវ.វស ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវ មេត្តាជ្រាបថាមកទល់ពេលនេះមានក្រសួង ស្ថាប័ន ភាគច្រើនបានអនុវត្តតាមស្មារតីនៃលិខិតលេខ ៧៨៣៨ សហវ.វស ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ទន្ទឹមនឹងនេះ នៅមានក្រសួង ស្ថាប័ន មួយចំនួនមិនទាន់បានអនុវត្តពេញលេញនៅឡើយ ដោយនៅមានការចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយដៃគូអភិវឌ្ឍន៍ ដែលមានភ្ជាប់ល័ក្ខខ័ណ្ឌពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជាកាតព្វកិច្ចបង់ពន្ធ អាករ និងការរួមចំណែកថវិកាបដិភាគជាដើម ដោយមិនមានការពិគ្រោះយោបល់ និងមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ដូចបានជម្រាបក្នុងលិខិតលេខ ៧៨៣៨ សហវ.វស ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បញ្ហានេះបង្កអោយមានផលវិបាកមួយចំនួនដូចជា :

-ការអនុវត្តនីតិវិធីហិរញ្ញវត្ថុមិនបានត្រឹមត្រូវ ដោយសារពេលវេលាប្រចុចញ៉ុច

-បង្កអោយមានការយឺតយ៉ាវក្នុងការអនុវត្តគម្រោង ដោយសារមិនបានដឹង និងត្រៀមលក្ខណៈជាមុន

-បង្កសម្ពាធមិនបានគ្រោងទុកដល់តណាទានថវិកាបដិភាគ

-ប៉ះពាល់ដល់សង្គតិភាពនៅក្នុងការអនុវត្តគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុ រវាងគម្រោង និងរវាងក្រសួង ស្ថាប័ន

ដើម្បីធានាអោយការអនុវត្តគម្រោងប្រព្រឹត្តទៅដោយរលូន ស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ជាពិសេស ត្រង់មាត្រា ៦៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមរំលឹកជាថ្មីម្តងទៀតអោយក្រសួង ស្ថាប័ននានា មុនពេលមានការឯកភាពតាមរូបភាពណាមួយជាមួយដៃគូអភិវឌ្ឍន៍ ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជា ការអនុញ្ញាតអោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ការចូលរួមបដិភាគជាសាច់ប្រាក់ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ។

ក្នុងករណីមិនមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនទេ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងមិនទទួលខុសត្រូវចំពោះការរាំងស្ទះដល់ការអនុវត្តគម្រោងឡើយ ។ ក្នុងករណីនេះ ប្រសិនបើពិនិត្យឃើញថា មានភាពចាំបាច់នឹងតម្រូវអោយប្រើប្រាស់ និងអនុវត្តនីតិវិធីជាធរមានក្នុងក្របខ័ណ្ឌនៃឥណទានថវិកាចរន្តនៃស្ថាប័ននោះផ្ទាល់តែម្តង ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងសូមផ្តល់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ឯកសារ-កាលប្បវត្តិ